ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល



៩

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ ដើម្បីជានាសង្គតិភាពនៃភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលដែលទទួលបន្ទុកអនុវត្តមុខងារគាំទ្រនិងសម្របសម្រួលរបស់ក្រសួង ស្ថាប័ន។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ លើកលែងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងក្រសួងការពារជាតិ។

## ជំពូកទី២
## ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន

**មាត្រា៣ .-**

ក្រសួង ស្ថាប័ន ត្រូវរៀបចំឱ្យមានអគ្គលេខាធិការដ្ឋាន ជាអង្គភាពរដ្ឋបាលកណ្តាលរបស់ក្រសួង ស្ថាប័ន ដើម្បីអនុវត្តមុខងារគាំទ្រនិងសម្របសម្រួលដោយត្រូវបំពេញភារកិច្ច ដូចខាងក្រោម៖

១- ធានានិរន្តរភាព និងដំណើរការប្រចាំថ្ងៃរបស់ក្រសួង ស្ថាប័ន ឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព រួមមាន ការគ្រប់គ្រង គាំទ្រ និងសម្របសម្រួលការងាររដ្ឋបាលទូទៅ ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ការរៀបចំ គ្រប់គ្រង និងប្រើប្រាស់ថវិកានិងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការគ្រប់គ្រងនិងរក្សាទុកឯកសារ និងទិន្នន័យស្ថិតិទាំងឡាយរបស់ក្រសួង ស្ថាប័ន។

២- ផ្តល់ការសម្របសម្រួល និងទំនាក់ទំនងទាំងឡាយដែលពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន ក្នុងក្របខ័ណ្ឌការងារទំនាក់ទំនងក្នុងនិងក្រៅក្រសួង ស្ថាប័ន រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងជួយសម្របសម្រួលលំហូរព័ត៌មាន និងការធានាដល់ភាគីពាក់ព័ន្ធនូវការផ្តល់ព័ត៌មានអំពីក្រសួង ស្ថាប័ន និងដែលពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន។

៣- គាំទ្រនិងសម្របសម្រួល ក្នុងការរៀបចំនិងអនុវត្តផែនការប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រ និងផែនការការងារផ្សេងទៀតរបស់ក្រសួង ស្ថាប័ន រួមទាំងការពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន ព្រមទាំងលើកឡើងនូវវិធានការនានាឬយុទ្ធសាស្ត្រដើម្បីកែលម្អសមិទ្ធកម្មឱ្យកាន់តែប្រសើរ។

៤- ផ្តល់ការគាំទ្រលើការរៀបចំគោលនយោបាយ និងកិច្ចការនីតិកម្មរបស់ក្រសួង ស្ថាប័ន រួមទាំងគាំទ្រដល់ការងារតាក់តែងនិងត្រួតពិនិត្យឯកសារគតិយុត្ត និងកិច្ចព្រមព្រៀងនានា ព្រមទាំងការធានានូវអនុលោមភាពនៃសកម្មភាពរបស់ក្រសួង ស្ថាប័ន ជាមួយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៥- គាំទ្រនិងសម្របសម្រួលការងារផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈក្នុងនាមក្រសួង ស្ថាប័ន រួមទាំងការសម្របសម្រួលនិងរៀបចំកិច្ចប្រជុំ សន្និសីទ និងព្រឹត្តិការណ៍ផ្សេងៗ ដើម្បីផ្តល់ព័ត៌មានដល់សាធារណជន។



៩

៦- គាំទ្រ សម្របសម្រួល និងជំរុញការងារបរិវត្តកម្មឌីជីថលក្នុងក្រសួង ស្ថាប័ន ដើម្បីធានានូវការបំពេញបេសកកម្មនិងមុខងាររបស់ក្រសួង ស្ថាប័ន ដោយរលូនប្រកបដោយសុខដុមនីយកម្ម មានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឆ្លើយតបនឹងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន។

៧- គាំទ្រ សម្របសម្រួល ជំរុញ និងធានានូវសង្គតិភាព សុខដុមនីយកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃការអនុវត្តវិធានការកែទម្រង់របស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន។

អគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន បំពេញភារកិច្ចដែលមានកំណត់ខាងលើ លើកលែងតែមានការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ឬដោយមានការសម្រេចដោយឡែកពីរាជរដ្ឋាភិបាល តាមការស្នើរបស់ក្រសួង ស្ថាប័នសាមី បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤ .-**

ការកែសម្រួលភារកិច្ចរបស់អគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ដែលមានចែងក្នុងមាត្រា៣ ខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ តាមការស្នើរបស់ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣

## រចនាសម្ព័ន្ធ

**មាត្រា៥ .-**

អគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន មានរចនាសម្ព័ន្ធចំណុះដើម្បីអនុវត្តភារកិច្ចដែលមានកំណត់ក្នុងមាត្រា៣ ខាងលើ ផ្អែកលើវិសាលភាពនិងភាពចាំបាច់នៃការងារ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន ឬអង្គភាពប្រហាក់ប្រហែលនៃអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់ក្រសួង ស្ថាប័នសាមី បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦.-**

អគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ត្រូវដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចអគ្គលេខាធិការត្រូវកំណត់ដោយព្រះរាជក្រឹត្យ។ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចអគ្គលេខាធិការរងត្រូវកំណត់ដោយអនុក្រឹត្យ ឬផ្អែកលើការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

នាយកដ្ឋាន និងអង្គភាពប្រហាក់ប្រហែលចំណុះអគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចប្រធាននាយកដ្ឋាន និងប្រធានអង្គភាពប្រហាក់ប្រហែល ត្រូវកំណត់ដោយអនុក្រឹត្យ។ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចអនុប្រធាននាយកដ្ឋាន និងអនុប្រធានអង្គភាពប្រហាក់ប្រហែលចុះក្រោម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី ឬតាមការកំណត់ផ្សេងផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន។



៩

**មាត្រា៧ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាន ឬអង្គភាពប្រហាក់ប្រហែលនៃអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី ឬតាមការកំណត់ផ្សេងផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការកែសម្រួលឈ្មោះជាអគ្គលេខាធិការដ្ឋាន

**មាត្រា៨ .-**

អង្គភាពរដ្ឋបាលកណ្ដាលរបស់ក្រសួង ស្ថាប័ន ដែលអនុវត្តមុខងារគាំទ្រនិងសម្របសម្រួល បច្ចុប្បន្នមានឈ្មោះជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គនាយកដ្ឋានកិច្ចការទូទៅ និងអគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ត្រូវបានកែសម្រួលឈ្មោះជាអគ្គលេខាធិការដ្ឋាន។

## ជំពូកទី៥
## ការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងមន្ត្រីដែលបំពេញការងារនៅអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន

**មាត្រា៩ .-**

ក្រសួងមុខងារសាធារណៈ ត្រូវដឹកនាំសម្របសម្រួលការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងមន្ត្រីដែលបំពេញការងារនៅអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

ការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងមន្ត្រីដែលបំពេញការងារនៅអគ្គលេខាធិការដ្ឋានត្រូវកំណត់ដោយអនុក្រឹត្យ តាមការស្នើរបស់ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១០ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ដែលមានចែងពាក់ព័ន្ធនឹងអគ្គលេខាធិកាដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គនាយកដ្ឋានកិច្ចការទូទៅ និងអគ្គនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ត្រូវបន្តមានសុពលភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័ន ដែលត្រូវបានប៉ះពាល់ដោយការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធថ្មីស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវរក្សាទុកអត្ថប្រយោជន៍ផ្នែកបៀវត្សយ៉ាងហោចក្នុងកម្រិតដដែល។



9

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ